# Overview of Galatians Khmer Version

## Verse by Verse Commentary of Galatians

Harley Voogd

## ទិដ្ឋភាពទូទៅនៃព្រះគម្ពីរកាឡាទី

**ជំពូកទីមួយៈ**

លោកប៉ូលនិយាយចំៗនៅក្នុងលិខិតនេះ។ លោកបានស្វែងយល់ឃើញថា ពួកជំនុំនៅស្រុកកាឡាទីបានងាកចេញពីដំណឹងល្អដ៏ពិត ហើយបែរជាទៅរកដំណឹងល្អមួយក្លែងក្លាយផ្សេងទៀត។ នៅក្នុងខទី៨ និង ៩ លោកប៉ូលបានលើកឡើងនូវសិទ្ធិអំណាចនៃដំណឹងល្អរបស់លោក។ លោកបាននិយាយថា បើមានទេវតាណាមួយ នាំដំណឹងល្អណាផ្សេងទៀតមកប្រាប់បងប្អូន សូមអោយទេវតានោះត្រូវបណ្តាសាទៅចុះ! ដូច្នេះ លោកប៉ូលជាមនុស្សដំបូងបំផុតដែលបានប្រកាសដំណឹងល្អដ៏ពិតដល់អ្នកស្រុកកាឡាទី។ (ចូរប្រយ័ត្នជាមួយនឹងទេវតាដែលមកបង្ហាញខ្លួននៅក្នុងបន្ទប់គេង របស់អ្នកនៅពាក់កណ្តាលយប់ ដ្បិតមានសាសនាខុសឆ្គង រឺគោលលទ្ធិផ្សេងៗត្រូវបានចាប់កំណើតឡើង ដោយសារតែការបង្ហាញខ្លួនរបស់ពួកគេទេវតាបែបនេះឯង។)

នៅក្នុងខទី១០ លោកប៉ូលបានបន្ត ដោយនិយាយថា លោកមិនខ្វល់ខ្វាយក្នុងការផ្គាប់ចិត្តមនុស្សលោកឡើយ។ លោកមិនបានខ្វល់ថាតើ ដំណឹងល្អដ៏ពិតប្រមាថដល់ជំនឿ រឺប្រពៃណីរបស់នរណាម្នាក់នោះឡើយ។ លោកបានពន្យល់យ៉ាងច្បាស់ថា បើលោកចង់ផ្គាប់ចិត្តមនុស្ស នោះលោកមិនចាំបាច់បំរើព្រះគ្រិស្តឡើយ។ យើងអាចឃើញនៅក្នុងលិខិតរបស់លោកប៉ូល ដ្បិតលោកបានព្យាករណ៍ថា នឹងមានមនុស្សនិយាយប្រឆាំងទាស់នឹងលោក ហើយលោកក៏ឆ្លើយតបទៅនឹងពាក្យចចាមអារាមវិញថា លោកបានឮពាក្យសំដីប្រឆាំងទាស់នឹងលោករួចទៅហើយ។

ចំណែកនៅក្នុងខទី១១-២៤វិញ លោកប៉ូលបានគាំទ្រដល់សិទ្ធិអំណាចរបស់លោក។ វាពិតជាពេលមួយគួរអោយរំភើប ដើម្បីរស់នៅ ប្រៀបដូចព្រះគម្ពីរត្រូវបានតាក់តែងឡើងម្តងទៀត។ ព្រះគម្ពីរដែលយើងមាននាពេលសព្វថ្ងៃនេះ មានលក្ខណៈពេញលេញ ហើយមិនត្រូវមាននរណាម្នាក់បន្ថែមអ្វីមួយពីលើ រឺ ដកហូតសេចក្តីណាមួយចេញនោះឡើយ

(វិវរណៈ ២២:១៨-១៩)។ ប៉ុន្តែ នៅសម័យរបស់លោកប៉ូល តាមពិតទៅ ទាំងលោកប៉ូល និង គ្រិស្តទូតដទៃទៀតកំពុងនិពន្ធព្រះគម្ពីរ។ សិទ្ធិអំណាចរបស់ពួកគេនេះ បានធ្វើអោយព្រះគម្ពីរមានភាពពេញលេញ និង មានភាពច្បាស់លាស់។ តើមានភស្តុតាងអ្វីខ្លះ ដែលពួកគេត្រូវទាមទារនូវសិទ្ធិអំណាចនេះ? តាមពិតទៅ ពួកគេមិនបានដឹងថា ពួកគេកំពុងតែសរសេរនូវព្រះគម្ពីរបច្ចុប្បន្ននេះឡើយ ប៉ុន្តែ ពួកគេបានដឹងជាក់ច្បាស់ថា ពួកគេកំពុងតែចាក់គ្រឹះមូលដ្ឋាន ដល់ប្រព័ន្ធនៃជំនឿមួយថ្មីទាំងស្រុង។ ពួកគ្រិស្តទូតដែលបាននៅជាមួយព្រះយេស៊ូ កាលព្រះយេស៊ូកំពុងបំពេញ ព័ន្ធកិច្ចរបស់ទ្រង់នៅលើផែនដីនេះ ក៏អាចទាមទារសិទ្ធិអំណាចចេញពីនេះបានដែរ។ លោកប៉ូលត្រូវតែពន្យល់ពីសិទ្ធិអំណាចរបស់លោកកាន់តែស៊ីជំរៅជាងនេះទៀត ព្រោះថា សិទ្ធិអំណាចរបស់លោកត្រូវបានវាយប្រហារពីសំណាក់អស់អ្នកដែលកំពុងតែប្រកាសនូវដំណឹងល្អខុសឆ្គងទៅកាន់ពួកជំនុំកាឡាទី។

នៅក្នុងខទី១១-១២ លោកប៉ូលលើកឡើងថា លោកផ្ទាល់បានទទួលចំណេះដឹងខាងដំណឹងល្អនេះមកពីព្រះគ្រិស្ត មិនមែនមកពីមនុស្សលោកឡើយ ដូចជាពួកគ្រិស្តទូតដទៃទៀតដែលបានរស់នៅជាមួយព្រះយេស៊ូ នៅពេលព្រះយេស៊ូបំពេញព័ន្ធកិច្ចនៅលើផែនដីនេះ។ លោកផ្ទាល់ក៏បានទទួលការបើកសំដែងពីព្រះគ្រិស្តផងដែរ។ លោកប៉ូលក៏លើកឡើងដែរថា ទោះបីជាលោកមានចិត្តខ្នះខ្នែងកាន់តាមសាសនាយូដាយ៉ាងរឹងមាំក៏ដោយ តាមពិតទៅ លោកត្រូវបានព្រះជាម្ចាស់ញែកទុកតាំងពីក្នុង "ផ្ទៃម្តាយរបស់លោក" មកម្ល៉េះ (ខ១៥) ដើម្បីប្រកាសពីដំណឹងល្អដ៏ពិតដល់សាសន៍ដទៃ។ ដូច្នេះ លោកប៉ូលបានបញ្ជាក់យ៉ាងច្បាស់ថា សិទ្ធិអំណាចរបស់លោកទទួលមកដោយផ្ទាល់ពីព្រះជាម្ចាស់ ដ្បិតលោកមិនបានជ្រើសរើសប្រកាសអំពីព្រះគ្រិស្តឡើយ ប៉ុន្តែ លោកត្រូវបានជ្រើសរើសតាំងពីយូរ មុនពេលដែលលោក បានទទួលជឿលើព្រះគ្រិស្តទៅទៀត។ ទោះបីជាបន្ទាប់ពីលោកបានទទួលជឿហើយក៏ដោយ ក៏លោកមិនបានទៅសួរយោបល់ "ពីសាច់ពីឈាម" ដែរ (ខ១៦) ប៉ុន្តែ លោកបែរជាធ្វើដំណើរទៅស្រុកអារ៉ាប់។ ជាច្រើនឆ្នាំបានកន្លងផុតទៅ មុនពេលដែលលោកប៉ូលបានមកស្នាក់នៅជាមួយគ្រិស្តទូតដំបូងគេ (លោកពេត្រុស និង លោកយ៉ាកុប)។

លោកនិយាយបន្តទៀតថា ការជឿរបស់លោកបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ដ្បិតរូបលោកផ្ទាល់ធ្លាប់ជាម្នាក់ដែលបៀតបៀនព្រះគ្រិស្ត ប៉ុន្តែ លោកបានប្រែក្លាយជាម្នាក់ដែលប្រកាសអំពីដំណឹងល្អព្រះគ្រិស្តទៅវិញ។ ប្រសិនបើ លោកប៉ូលមិនមានសិទ្ធិអំណាច ដើម្បីប្រកាស និង បង្រៀនអំពីព្រះគ្រិស្ត តើធ្វើដូចម្តេចអោយលោកអាចពន្យល់អំពីការពិតទាំងអស់នេះបាន? វាលុះត្រាតែលោកប៉ូលជាមនុស្សឆ្កួតរឺ?អ្នកស្រុកកាឡាទីបានទទួលលោកដំបូងគេបំផុត (កាឡាទី ៤:១៤) ដូច្នេះ ពួកគេពិតជា មិនបានគិតថា លោកជាមនុស្សឆ្កួតនោះទេ។

**ជំពូកទីពីរ:**

នៅក្នុងខទី១-១០ លោកប៉ូលបន្តនិយាយអំពីទីចាប់ផ្តើមរបស់លោក។ លោកលើកឡើងអំពីគ្រូខុសឆ្គងជាច្រើន ដែលព្យាយាមនាំមនុស្សអោយប្រព្រឹត្តតាមក្រឹត្យវិន័យវិញ ដ្បិតពួកគេទាំងនោះបានមានសេរីភាព ដោយក្នុងអង្គព្រះគ្រិស្ត។ លោកប៉ូលរៀបរាប់ថា លោកពេត្រុស លោកយ៉ាកុប* និង លោកយ៉ូហាន បានយល់ព្រមជាមួយនឹងភាពជាគ្រិស្តទូតរបស់លោករួចទៅហើយ។ ការនេះកើតឡើងតាំងពី១៤ឆ្នាំ បន្ទាប់ពីទស្សនកិច្ចដំបូងរបស់លោកប៉ូលទៅកាន់ក្រុងយេរូសាឡឹម។ ព្រះគម្ពីរកិច្ចការ ជំពូក១១ រឺ១៥ ប្រហែលជាមានភាពស្រដៀងនឹងព្រះគម្ពីរកាឡាទីជំពូកទី២ ដែលពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចលើកទីពីររបស់លោកប៉ូល (ក្រុមប្រឹក្សានៅក្រុងយេរូសាឡឹម)។ លោកប៉ូលកំពុងតែពណ៌នាអំពីព្រឹត្តិការណ៍នៅក្នុងក្រុងយេរូសាឡឹម ដើម្បីបង្ហាញអោយឃើញនូវបញ្ហារវាងអ្នកកាន់សាសនាយូដា និង គ្រិស្តបរិស័ទ ដែលបានចូលក្នុងក្រុមប្រឹក្សានេះ។លោកប៉ូលមានភាពឈ្លាសវៃណាស់។ លោកប៉ូល និង លោកទីតុសបានទៅជួបជាមួយអ្នកដឹកនាំក្រុមជំនុំជាលក្ខណៈបុគ្គលជាមុនសិន ដើម្បីបញ្ចុះបញ្ចូលពួកគេថា ការកាត់ស្បែកមិនមានភាពចាំបាច់សំរាប់ការសង្គ្រោះឡើយ ហើយការបណ្តែតបណ្តោយខ្លួនទៅនឹងការនេះ វាពិតជាមានគ្រោះថ្នាក់ខ្លាំងណាស់ ដ្បិតវានាំអោយបងប្អូនសាសន៍យូដាមានការភាន់ច្រលំអំពីរបៀបដែលមនុស្សម្នាក់អាចទទួលការសង្គ្រោះ (ខ២-៤)។ *លោកយ៉ាកុបជាបងប្អូនរបស់ព្រះយេស៊ូ។ គ្រិស្តទូតយ៉ាកុបបានទទួលមរណៈភាព បាត់ទៅហើយ។

នៅក្នុងខទី១១-២១ លោកប៉ូលប្រាប់អំពីសាច់រឿងដែលនាំអោយលោកប្រឆាំងនឹងលោកពេត្រុសនៅទីក្រុងអន់ទីយ៉ូក ពាក់ព័ន្ធទៅនឹងការសំរបសំរួលរបស់លោកប៉ូលជាមួយពួកសាសន៍យូដា។ លោកប៉ូលបានស្តីបន្ទោសលោកពេត្រុសនៅទីសាធារណៈ។ កំហុសរបស់លោកប៉ូលបែបនេះត្រូវតែដោះស្រាយបែបនេះឯង។ ប្រហែលជាពេលនោះ លោកពេត្រុសបាននឹកឃើញពីពេលដែលលោកបាននៅជាមួយព្រះយេស៊ូ ហើយលោកប្រាកដជាបានឃើញពីសិទ្ធិអំណាចរបស់ព្រះគ្រិស្តដែលមាននៅក្នុងលោកប៉ូលហើយ។ ព្រះយេស៊ូបានមានព្រះបន្ទូលប្រឆាំងទៅនឹងពួកផារីស៊ីទាក់ទងនឹងសាសនាខុសឆ្គងរបស់ពួកគេ។ ឥឡូវនេះ លោកប៉ូលបានកំពុងតែស្តីបន្ទោសទាស់នឹងចំណុចខ្សោយ និង ការសំរបសំរួលរបស់លោកពេត្រុសទៅនឹងការបង្រៀនខុសឆ្គង។ លោកប៉ូលពណ៌នាយ៉ាងលម្អិតអំពីអ្វីដែលលោកបាននិយាយទៅកាន់លោកពេត្រុស។ លោកប៉ូលបង្ហាញថា បញ្ហាទាំងនេះថែមទាំងធ្វើអោយលោកពេត្រុសកាន់តែមានក្លិនស្អុយ។ ដូច្នេះហើយ លោកប៉ូលមានសិទ្ធិអំណាច ដើម្បីស្តីបន្ទោសលោកពេត្រុសនៅទីសាធារណៈបាន។ លោកប៉ូលបានបន្តពន្យល់ទៀតថា មនុស្សបានទទួលការសង្គ្រោះដោយសារតែគេមានជំនឿលើព្រះគ្រិស្ត មិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ។

**ជំពូកទីបី:**

នៅក្នុងខទី១-៥ លោកប៉ូលប្រាប់អោយអ្នកស្រុកកាឡាទីគិត។ លោកបង្ហាញពួកគេថា ពួកគេកំពុងតែដើរត្រឡប់ក្រោយហើយ។ លោកប៉ូលសួរថា: "ពីជំនឿទៅកាន់ក្រឹត្យវិន័យ?" និង "ពីព្រះវិញ្ញាណទៅកាន់សាច់ឈាម?" តើអ្វីដែលបានចាប់ផ្តើមនៅក្នុងព្រះវិញ្ញាណ និង ជំនឿ បែរជាត្រូវបញ្ចប់នៅក្នុងសាច់ឈាម និង ក្រឹត្យវិន័យវិញឬ? លោកប៉ូលហៅពួកគេថា ជាមនុស្សល្ងីល្ងើ ដែលមានគំនិតគិតបែបនេះ។

ខទី៦-៩ លោកប៉ូលពណ៌នាអំពីព្រះបន្ទូលសន្យាចំពោះលោកអប្រាហាំ ដែលថា លោកអប្រាហាំបានសង្គ្រោះដោយសារជំនឿរបស់លោក។ ដោយសារតែលោកអប្រាហាំបានសង្គ្រោះ ដោយជំនឿហើយ ទើបកូនចៅរបស់លោក

នឹងត្រូវទទួលការសង្គ្រោះ ដោយជំនឿដែរ (កូនចៅខាងវិញ្ញាណរបស់លោក)។ លោកអប្រាហាំមិនបានទទួលការសង្គ្រោះ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យនោះទេ ដូច្នេះ កូនចៅរបស់លោកក៏នឹងមិនទទួលការសង្គ្រោះ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យដែរ។នៅក្នុងខទី១០-១៤ លោកប៉ូលបង្រៀនអំពីក្រឹត្យវិន័យ ដែលប្រើភស្តុតាងបទគម្ពីរ (ដូចជានៅក្នុងខទី៨ លោកបានដកស្រង់ចេញពីលោកុប្បត្តិ ១២:៣)។ លោកដកស្រង់ចេញពីបទគម្ពីរទុតិយកថា ២៧:២៦ ចែងថា អ្នកណាមិនគោរពសេចក្ដីដែលមានចែងទុកក្នុងក្រឹត្យវិន័យ ហើយមិនប្រតិបត្តិតាមទេ អ្នកនោះមុខជាត្រូវបណ្ដាសាពុំខាន!។ លោកដកស្រង់ចេញពីបទគម្ពីរហេប្រឺ ២:៤ ចែងថា មនុស្សសុចរិតរស់នៅដោយជំនឿ។ ដូច្នេះហើយទើបពួកគេត្រូវបានគេហៅថា ជាមនុស្សសុចរិត (នៅក្នុងខទី៦ លោកប៉ូលដកស្រង់ចេញពីបទគម្ពីរលោកុប្បត្តិ ១៥:៦ ដែលចែងថា លោកអប្រាហាំជឿលើព្រះជាម្ចាស់ ហើយព្រះអង្គប្រោសលោកអោយបានសុចរិតដោយយល់ដល់ជំនឿនេះ។)

នៅក្នុងខទី១២ លោកប៉ូលបង្រៀនថា ក្រឹត្យវិន័យខុសប្លែកពីជំនឿទាំងស្រុង ដ្បិតវាជាការប្រព្រឹត្តនៃ "ការសង្គ្រោះខ្លួនឯង" ដើម្បីខ្នះខ្នែងខំរស់នៅតាមក្រឹត្យវិន័យខាងក្រៅ។ លោកដកស្រង់ចេញពីបទគម្ពីរលេវីវិន័យ ១៨:៥។ អ្នកណាដែលរស់នៅតាមក្រឹត្យវិន័យ ជាជាងរស់នៅតាមជំនឿលើអ្វីដែលព្រះគ្រិស្តបានធ្វើ អ្នកនោះនឹងមានជីវិតតាមវិន័យទាំង នោះ ហើយនឹងក្លាយទៅជាទាសករនៃក្រឹត្យវិន័យ។ អ្នកនោះត្រូវជាប់គាំងក្នុងបំណងដ៏ឥតខ្លឹមសារនៃ "ការសង្គ្រោះ ដោយខ្លួនឯង" (សូមមើល រ៉ូម ១០:៥-៥)។ មនុស្សដែលកាន់តាមក្រឹត្យវិន័យ ក៏នឹងត្រូវកាត់ទោសស្របតាមអំពើ របស់ខ្លួន ដើម្បីធ្វើតាមក្រឹត្យវិន័យនោះដែរ (សូមមើល យ៉ូហាន ៥:៤៥-៤៧)។ នៅក្នុងខទី១៣ លោកប៉ូលបង្ហាញថា ព្រះគ្រិស្តដោះយើងអោយមានសេរីភាពពីក្រឹត្យវិន័យ ដោយទទួលយកនូវបណ្ដាសាជំនួសយើង តាមរយៈការជាប់ឆ្កាងនៅលើដើមឈើ (សូមមើល ទុតិយកថា ២១:២៣ យ៉ូស្វេ ១០:២៦-២៧)។ ក្រឹត្យវិន័យចេញពីមេទាសករខាងក្រៅ ទៅជានិស្ស័យថ្មីនៅក្នុងអ្នកជឿដែលកើតជាថ្មី (សូមមើលយេរេមា ៣១:៣១-៣៤ អេសេគាល ១១:១៩)។នៅក្នុង ខទី១៤ លោកប៉ូលលើកឡើងថា តាមរយៈព្រះគ្រិស្ត

ព្រះបន្ទូលសន្យាសំរាប់លោកអប្រាហាំ ក៏សំរាប់សាសន៍ដទៃផងដែរ ហើយព្រះបន្ទូលសន្យានៃព្រះវិញ្ញាណតាមរយៈជំនឿ មិនមែនដោយសារអំពើរបស់ខ្លួនឡើយ (សូមមើល អេសាយ ៥២:១០)

នៅក្នុងខទី១៥-១៨ និយាយអំពីព្រះបន្ទូលសន្យាដែលលោកអប្រាហាំបានទទួលៈ ពីមុនក្រឹត្យវិន័យ និង មិនដែលលុបបំបាត់ចោលដោយក្រឹត្យវិន័យឡើយ។ លោកប៉ូលលើកឡើងថា នៅពេលដែលសម្ពន្ធមេត្រីត្រូវបានធ្វើសច្ចាប័នហើយ (ព្រមព្រៀង) វាមិនអាចបន្ថែមពីលើ រឺក៏ដកចេញវិញបានឡើយ។ លោកបង្ហាញថា ព្រះបន្ទូលសន្យាត្រូវបានផ្តល់ដល់លោកអប្រាហាំ និង ពូជពង្សរបស់លោក មិនមែនសំរាប់ពូជពង្សទាំងឡាយឡើយ។ ពាក្យថាពូជពង្សនោះជាពាក្យឯកវចនៈ គឺចង់សំដៅទៅលើព្រះគ្រិស្ត។ តើព្រះបន្ទូលសន្យានោះគឺជាអ្វី? ជាព្រះបន្ទូលសន្យាអំពីដំណឹងល្អ គឺដំណឹងល្អដែលព្រះគ្រិស្តត្រូវសុគតសំរាប់មនុស្សមានបាប និង អំពីការសុគតរបស់ទ្រង់សំរាប់អស់អ្នកដែលជឿលើទ្រង់ ដោយជំនឿ។ ព្រះបន្ទូលសន្យាត្រូវបានផ្តល់ដល់ពូជពង្សមួយ (ឯកវចនៈ សូមមើលលោកុប្បត្តិ ៣:១៥ ២១:១២ ២២:១៨ រ៉ូម ៩:៦-៧ ហេព្រើ ១១:១៧-១៨)។ ទោះបីជាក្រឹត្យវិន័យត្រូវបានផ្តល់ដល់លោកម៉ូសេក៏ដោយ ក៏ព្រះបន្ទូលសន្យានៅស្ថិតស្ថេររហូតដល់វាត្រូវបានបំពេញនៅក្នុងព្រះគ្រិស្ត។

តើហេតុអ្វីបានជាមានក្រឹត្យវិន័យផ្តល់ដល់លោកម៉ូសេដូច្នេះ? (ទុតិយកថា ៩:៨-៩ ទំនុក ១៨៧:១៩-២០) នៅខទី១៩: វាត្រូវបានបន្ថែមមក ដោយសារតែការល្មើសច្បាប់ រឺ "ការធ្វើល្មើស" (ភាសាក្រិក) រឺ ការធ្វើរំលោភ។ តើមនុស្សអាចដឹងថាខ្លួនធ្វើល្មើសដូចម្តេចកើត បើសិនជាគ្មាននរណាម្នាក់ប្រាប់គាត់នោះ? និយមន័យជាភាសាក្រិក Thayer នៃពាក្យបទល្មើសគឺ "ជាអំពើបាបដែលអាចកើតមាននៅលើអត្តចរិតនៃការល្មើស ហើយក្រោយមកវានាំអោយមានការយល់ដឹងពីអំពើបាបកាន់តែខ្លាំង និង មានបំណងចិត្តសំរាប់ការប្រោះលោះ។" (សូមមើល រ៉ូម ៧:៧-១៣)។ ក្រឹត្យវិន័យត្រូវបានផ្តល់មក ដើម្បីបង្ហាញពីអំពើបាបដ៏ពិតដែលមាននៅខាងក្នុងយើង ដើម្បីជាស់តឿន

យើងអោយឃើញថា យើងត្រូវបានពុករលួយដោយសារតែអំពើបាប ហើយវាក៏ជួយយើងអោយស្គាល់ពីតំរូវការដ៏ចាំបាច់ក្នុងការត្រូវការព្រះសង្គ្រោះ។ ដូច្នេះ ក្រឹត្យវិន័យប្រៀបដូចជាសន្ទុះនៃការឆក់ខ្សែភ្លើង ដែលភ្លាមៗផ្តល់ជីវិតដល់ សាកសព មុនពេលដែលវាត្រូវស្លាប់ទៅវិញម្តងទៀត។ ក្រឹត្យវិន័យជាមិត្តសំឡាញ់ផង និង ជាសត្រូវផង។វាជាមិត្ត សំឡាញ់ នៅពេលដែលវាជំរុញយើងអោយស្វែងរកព្រះដែលប្រោះលោះយើង ហើយវាជាសត្រូវ នៅពេលដែលវាថ្កោលទោសយើងអោយចុះនរក។ ក្នុងករណីទាំងពីរនេះ ក្រឹត្យវិន័យនៅតែល្អ។ វាគឺជារូបយើងទេ ដែលជាមនុស្សអាក្រក់។

ក្រឹត្យវិន័យត្រូវបានផ្តល់មកតាមរយៈពួកទេវតា (សូមមើល ទុតិយ ៣៣:២-៤ កិច្ចការ ៧:៥២-៥៣ ហេប្រឺ ២:២)។ ទុតិយកថា ៣៣:២ ចែងថា ព្រះជាម្ចាស់បានបញ្ជូននូវ "ក្រឹត្យវិន័យដ៏ឆេះសន្ធោសន្ធៅ"មួយ ចេញពីព្រះហស្តស្តាំរបស់ទ្រង់ ដែលត្រូវបានចែកចាយតាមរយៈពួកទេវតា ហើយក្រឹត្យវិន័យនេះត្រូវបានហុចបន្តដល់លោកម៉ូសេ (សូមមើល កិច្ចការ ៧:៣៧-៣៨ ៧:៥២-៥៣)។ដោយមានឋានៈទាបជាងពួកទេវតា លោកម៉ូសេគឺជាអ្នកជួយអន្តរាគមន៍រវាង ព្រះជាម្ចាស់ និង អស់អ្នកដែលបានរស់នៅក្នុងសម័យ ដែលពួកគេកំពុងរង់ចាំពូជពង្សមួយយាងមក។ នៅក្នុង ទុតិយ ៥:១-៥ លោកម៉ូសេមានប្រសាសន៍ថា ក្រឹត្យវិន័យ (វីសម្ពន្ធមេត្រី) ដែលបានផ្តល់ដល់ពួកគេ នៅពេលនោះ (ខទី៣) សំរាប់ពេលនោះ និង មិនមែនសំរាប់បុព្វបុរសរបស់ពួកគេឡើយ (លោកអប្រាហាំ អ៊ីសាក និង យ៉ាកុប)។ សម្ពន្ធមេត្រីដែលបានផ្តល់ដល់លោកអប្រាហាំ គឺជាពូជពង្សមួយដែលត្រូវយាងមក គឺព្រះយេស៊ូគ្រិស្ត ដែលមានឋានៈខ្ពស់ជាងពួកទេវតា (ហេប្រឺ ១:១៣)

នៅក្នុងខទី២០ លោកប៉ូលមានប្រសាសន៍ថា នៅទីណាដែលមានអ្នកអន្តរាគមន៍ ទីនោះមានភាគីពីរដែលមានទាក់ទង និងកិច្ចព្រមព្រៀង (សូមមើល លេវី ២៦:៤៦)។ វត្តមានរបស់អ្នកអន្តរាគមន៍បញ្ជាក់នូវវត្តមានភាគីកិច្ចព្រមព្រៀង លើសពីម្នាក់។ ដូច្នេះ ព្រះយេស៊ូគឺជាអ្នកអន្តរាគមន៍ដ៏ពិសេសម្នាក់ ដ្បិតទ្រង់គឺជាអ្នកអន្តរាគមន៍នៃព្រះបន្ទូលសន្យា

(ហេព្រឺ ៨:៦ ៩:១៥ ១២:២៤) ហើយព្រះបន្ទូលសន្យាមានតែភាគីទទួលខុសត្រូវតែមួយគត់ គឺជាព្រះដែលបានសន្យា។ ព្រះជាម្ចាស់បានមានព្រះបន្ទូលសន្យាដល់លោកអប្រាហាំ ហើយព្រះយេស៊ូគឺជាអ្នកអន្តរាគមន៍នៃព្រះបន្ទូលសន្យានោះ ប៉ុន្តែ ជំនួសអោយភាគីពីរនាក់ វាមានភាគីតែម្នាក់ប៉ុណ្ណោះ។ "ព្រះជាម្ចាស់ជាអង្គតែមួយ" (ខ២០)។ ព្រះបន្ទូលសន្យាគឺជាការបង្ហាញពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។ វាមិនមែនជាកិច្ចព្រមព្រៀងមួយនោះទេ ដ្បិតព្រះជាម្ចាស់គឺជាភាគីនៃការសំរេចចិត្តតែមួយគត់នៅក្នុងសេចក្តីសន្យា។ ព្រះបន្ទូលសន្យាបានសំរេចមិនមែនដោយសារតែយើងធ្វើផ្នែករបស់យើងនោះទេ ប៉ុន្តែ វាត្រូវការភាគីទាំងសងខាង។ វាជាព្រះបន្ទូលសន្យាដែលគ្មានលក្ខខណ្ឌ។ ព្រះយេស៊ូ ដែលជាអ្នកអន្តរាគមន៍ បានបំពេញតាមព្រះបន្ទូលសន្យាសំរាប់ភាគីដែលបានសំរេចចិត្ត (ព្រះជាម្ចាស់) ហើយភាគីអ្នកទទួលនឹងទទួលដោយគ្មានលក្ខខណ្ឌ។ ដរាបណា ការសង្គ្រោះនៅតែមាន (ហើយប្រហែលជាលើសនេះទៅទៀត) លោកម៉ូសេជាអ្នកអន្តរាគមន៍នៅក្នុងប្រភេទនៃកិច្ចព្រមព្រៀង "បើអ្នកធ្វើនេះ ខ្ញុំនឹងធ្វើនោះ" (ក្រឹត្យវិន័យ/ភាពជាបូជាចារ្យម៉ូសេ)។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះយេស៊ូគឺជាអ្នកអន្តរាគមន៍នៅក្នុងប្រភេទនៃសម្ពន្ធមេត្រីភាព "ខ្ញុំនឹងធ្វើវាទាំងអស់"។ ដរាបណាការសង្គ្រោះនៅតែត្រូវបានគិត (យើងឈរដោយសុចរិតនៅមុខព្រះជាម្ចាស់ ស្វាគមន៍ចូលក្នុងព្រះវត្តមានព្រះជាម្ចាស់ អំពើបាបរបស់យើងត្រូវបានអត់ទោស/បំភ្លេច គ្មានសេចក្តីក្រោធ) យើងមិនត្រូវធ្វើអ្វីទាំងអស់ គឺយើងគ្រាន់តែជឿថា ព្រះយេស៊ូបានធ្វើអ្វីៗទាំងអស់ ហើយយើងគ្រាន់តែមានទំនុកចិត្តដូចកូនក្មេងទៅលើទ្រង់ ដើម្បីសង្គ្រោះយើង។ តើមនុស្សគ្មានទំនួលខុសត្រូវទេឬ? ទំនួលខុសត្រូវរបស់មនុស្សយើងគឺ ជំនឿ និង ការស្តាប់បង្គាប់ (ការស្តាប់បង្គាប់តែងតែស្ថិតនៅក្រោមព្រះគុណរបស់ព្រះជាម្ចាស់) សូមបងប្អូនខិតខំធ្វើការ ទាំងគោរពកោតខ្លាច និង ញាប់ញ័រស្របតាមការសង្គ្រោះដែលបងប្អូនបានទទួល (ភីលីព ២:១២)។ ប៉ុន្តែ វាមានអ្វីច្រើនទៀតសំរាប់យើងដែលត្រូវធ្វើ លើសពីជំនឿ និង ការស្តាប់បង្គាប់ គឺត្រូវប្តេជ្ញាធ្វើបទល្មើសដូចជាពួកយូដាបានប្តេជ្ញាប្រឆាំងនឹងដំណឹងល្អរបស់លោកប៉ូល (រ៉ូម ១៦:២៥)

នៅក្នុងខទី២១-២៣ លោកប៉ូលមានប្រសាសន៍ថា ក្រឹត្យវិន័យគឺជាការល្អ ហើយវាមិនប្រឆាំងទាស់នឹងព្រះបន្ទូលសន្យាឡើយ។ ក្រឹត្យវិន័យមិនអាចសង្គ្រោះយើងបានឡើយ ហើយគោលបំណងរបស់វាក៏មិនមែនមកសង្គ្រោះមនុស្សដែរ។

ខទី២២-២៣ ដូចទៅខទី៨ នៅពេលវាចែងថា បទគម្ពីរកំពុងតែរៀបចំមនុស្សទាំងអស់អោយបំពេញតាមព្រះបន្ទូលសន្យានៅក្នុងការងាររបស់ព្រះគ្រិស្ត។ ដូច្នេះ ព្រះគ្រិស្ត (ព្រះបន្ទូលបានក្លាយជាសាច់ឈាម) បានប្រើក្រឹត្យវិន័យដើម្បីចាក់សោរមនុស្សគ្រប់គ្នាអោយមានសុវត្ថិភាព ដូច្នេះ ព្រះបន្ទូលសន្យាអាចផ្តល់ដល់អស់អ្នកដែលជឿ ខណះពេលអស់អ្នកដែលមិនជឿនឹងបន្តនៅស្ថិតក្នុងមន្ទីរឃុំឃាំងនៃក្រឹត្យវិន័យ ដែលត្រូវទទួលការថ្កោលទោស (សូមមើល និក្ខម ១៤:៣ ជនគណនា ១៤:២២-២៤ រ៉ូម ៩:៦)។ វាប្រៀបបីដូចជាបទគម្ពីរចាប់យកមនុស្សទាំងអស់ដាក់ទៅក្នុងសំណាញ់ដ៏ធំមួយ (សំណាញ់ច្បាប់) (សូមមើល ម៉ាថាយ ១៣:៤៧-៥១)

នៅក្នុងខទី២៤-២៥ លោកប៉ូលហៅក្រឹត្យវិន័យជាគ្រូណែនាំ។ គ្រូណែនាំនៅសម័យរបស់លោកប៉ូលគឺជាអ្នកថែរក្សាលើកុមារប្រុសនៅថ្នាក់ខ្ពស់។ ក្មេងប្រុសៗនោះមិនអនុញ្ញាតអោយចេញទៅណា ដោយគ្មានគ្រូណែនាំឡើយ។ គ្រូណែនាំមើលការខុសត្រូវក្នុងការអប់រំសីលធម៌ក្មេងប្រុសៗ (និយមន័យភាសាក្រិកThayer)។ ពាក្យថា "នាយកសាលា" ជាការបកប្រែម៉្យាងនៃភាសាក្រិក ប៉ុន្តែ នៅក្នុងការបកប្រែម៉្យាងទៀតគឺ "អ្នកមើលការខុសត្រូវ" រឺ "អាណាព្យាបាល" (Vincent Word Studies)។ ក្នុងនាមជាគ្រូណែនាំ គាត់ត្រូវប្រាប់ពីច្បាប់អោយបានញឹកញាប់ដល់មនុស្ស ដើម្បីអោយពួកគេចងចាំពីភាពអសមត្ថភាពរបស់ពួកគេក្នុងការធ្វើតាមច្បាប់ដោយល្អឥតខ្ចោះ និង ដើម្បីអោយពួកគេចងចាំពីភាពពឹងអាងរបស់ពួកគេលើព្រះជាម្ចាស់។ គ្រូណែនាំដាក់កម្រិតមនុស្សយ៉ាងតឹងរ៉ឹង ក្នុងការអោបក្រសោបអំពើបាបដោយអោយពួកគេធ្វើតាមបទបញ្ញាយ៉ាងតឹងរ៉ឹង និង ទារុណកម្មដ៏សាហាវ (សូមមើល និក្ខមនំ ជនគណនា លេវីវិន័យ ទុតិយកថា)។ ក្រឹត្យវិន័យគឺជាគ្រូណែនាំដល់សាសន៍អ៊ីស្រាអែលដែលមាន "ឋានៈខ្ពស់" ប៉ុន្តែ សាសន៍ដទៃដែលមាន "ឋានៈទាប" វិញត្រូវបានអនុញ្ញាតអោយ "មានសេរីភាព" (សូមមើល ទុតិយកថា ៩:៨ ទំនុក ១៤៧:២០ ម៉ាកុស ៧:២៧ រ៉ូម ៩:២៤ កាឡាទី ២:១៥ អេភេ ២:១២ កិច្ចការ ១៧:៣០-៣១)

ប៉ុន្តែ នៅក្នុងខទី២៥វិញចែងថា យើងលែងស្ថិតនៅក្រោមឱវាទរបស់អ្វីដែលណែនាំយើងនោះទៀតហើយ គឺយើងរស់នៅដោយសារជំនឿវិញ។ តាមរយៈជំនឿ យើងក្លាយជាកូនរបស់ព្រះជាម្ចាស់។ សូមអានរ៉ូម ៨:១៥។ យើងទទួល

ព្រះវិញ្ញាណដែលយកយើងជាកូន តាមរយៈជំនឿរបស់យើងនៅក្នុងព្រះគ្រិស្ត។ ពាក្យថា ទទួលយកជាកូន មិនមែនសំដៅលើ ការទទួលយកកុមារ ដែលត្រូវឪពុកម្តាយបោះបង់ចោលនោះឡើយ ប៉ុន្តែ វាស្របតាមវប្បធម៌រ៉ូម៉ាំង ដែលបុរសម្នាក់អាចទទួលយកកូនប្រុសរបស់គាត់ ធ្វើជាកូនពេញសិទ្ធិ។ ពាក្យជាភាសាក្រិក ដែលលោកប៉ូលប្រើនេះមានន័យថា: "តែងតាំងនរណាម្នាក់ក្នុងឋានៈជាកូនប្រុស" និង ចង់សំដៅកេរ្តិ៍មរតកស្របច្បាប់ដែលគាត់អាចទទួលបានពីក្រុមគ្រួសារក្នុងឋានៈជាអ្នកស្នង។ អ្នកស្រុករ៉ូម៉ាំងអាចបដិសេធកូនរបស់ខ្លួនដោយស្របច្បាប់ និង អាចបណ្តេញពួកគេចេញពីផ្ទះរបស់ខ្លួនបាន។ នៅពេលដែលកូនត្រូវបានទទួលយកដោយឪពុកបង្កើតខ្លួន កូននោះនឹងអាចមានសិទ្ធិហៅថាជាកូនប្រុស។ គ្រូណែនាំគឺជាអ្នកមើលថែតែមួយគត់លើក្មេងប្រុសៗដែលមិនទាន់ពេញវ័យ។ គ្រូណែនាំនឹងរៀបចំក្មេងប្រុសនោះ អោយក្លាយជាកូនប្រុសពេញលេញ។ ជំនឿរបស់យើងនៅក្នុងព្រះយេស៊ូ នឹងនាំយើងអោយក្លាយជាកូនពេញសិទ្ធិរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរប្រើពាក្យថា (កូនៗ) (Children) នៅក្នុងខទី២៦ ប៉ុន្តែ វាមានប្រយោជន៍ជាងដែលប្រើពាក្យ "កូនប្រុស" ដ្បិតក្នុងនាមយើងជាកូនៗ យើងស្ថិតនៅក្រោមគ្រូណែនាំ ប៉ុន្តែក្នុងនាមយើងជាកូនប្រុសវិញ យើងមានឋានៈខ្ពស់ជាងគ្រូណែនាំ (សូមមើល ៤:១៤-១៧)

(ខទី២៧-២៩) ឥឡូវនេះ អស់អ្នកដែលជឿលើព្រះគ្រិស្ត និង បានទទួលពិធីជ្រមុជទឹករួមជាមួយព្រះគ្រិស្ត ក្លាយជាកូនពេញសិទ្ធិរបស់ព្រះជាម្ចាស់ ដោយមិនប្រកាន់អំពីពូជសាសន៍ ភេទ រឺឋានៈក្នុងសង្គមទៀតហើយ។ អស់អ្នកដែលជឿគឺជាអ្នកត្រូវស្នងកេរ្តិ៍មរតកនូវព្រះបន្ទូលសន្យាដែលបានផ្តល់ដល់លោកអប្រាហាំ និង មានសេរីភាពពីក្រឹត្យវិន័យរបស់លោកម៉ូសេ។ យើងមិនអាចធ្វើល្មើសនឹងច្បាប់ទៀតឡើយ ដ្បិតឥឡូវនេះ ច្បាប់នោះវាស្ថិតនៅក្នុងយើង ដោយសារតែព្រះគ្រិស្តបានផ្តល់អោយយើងនូវដួងចិត្តមួយថ្មី (អេសេគាល ៣៦:២៦-២៧ យេរេ ៣១:៣១-៣៤)។ បន្ទះថ្មនៃក្រឹត្យវិន័យនឹងត្រូវដកចេញ ហើយជំនួសមកវិញដោយព្រះបន្ទូលដ៏មានព្រះជន្មរស់។ អស់អ្នកដែលប្រើប្រាស់អ្វីដែលព្រះគ្រិស្តបានធ្វើ មកធ្វើជាលេសដើម្បីប្រព្រឹត្តអំពើបាប ហាក់ដូចជាពួកគេមិនយល់ពីអត្ថន័យដ៏ពិតនៃការសង្គ្រោះអញ្ចឹង (រ៉ូម ៦:១-៧)។ មនុស្សដែលបានទទួលដួងចិត្តថ្មី នឹងស្អប់អំពើបាប។ អស់អ្នកដែលស្អប់អំពើបាបមានចិត្តដូចជាព្រះបិតារបស់ពួកគេដែរ។ ចំណែកឯមនុស្សដែលស្រឡាញ់អំពើបាប មានដួងចិត្តដែលស្អប់ព្រះជាម្ចាស់

តាមពិតទៅ ពួកគេមានចិត្តដូចជាឪពុករបស់ពួកគេគឺអារក្សសាតាំង (សូមមើល ៨:៤២-៤៧)។ កូនដែលមានដួងចិត្តដូច ជាព្រះបិតា (ព្រះជាម្ចាស់) ដែលទ្រង់បានទទួលយកជាកូន និង បានទទួលយកដោយព្រះបិតា។ ប៉ុន្តែ កូនដែល មានចិត្តផ្ទុយនឹងព្រះបិតាវិញ នឹងត្រូវបដិសេធដោយព្រះបិតា។

**ជំពូកទីបួន:**

៤ទី១-២ លោកប៉ូលពណ៌នាពីអ្វីដែលកើតមាននៅក្នុងផ្ទះអភិជន រឺព្រះរាជវង្ស គឺកូនមិនខុសពីខ្ញុំបំរើឡើយ។ ពួកគេ មិនអាចបញ្ជាអ្នកផ្ទះបានឡើយ ហើយពួកគេក៏ត្រូវធ្វើតាមច្បាប់ ដែលពួកខ្ញុំបំរើធ្វើដែរ។ អ្នកបំរើនឹងមានសិទ្ធិអំណាច លើកូនរបស់ម្ចាស់ខ្លួន។ ប៉ុន្តែ នៅពេលដែលកូននោះចំរើនវ័យធំឡើង និង នៅពេលដែលពួកគេពេញវ័យ អ្នកបំរើនោះត្រូវតែចុះចូលនឹងអស់អ្នកដែលពួកគេធ្លាប់មិនសិទ្ធិអំណាចលើនោះវិញ។

នៅក្នុង៤ទី៣ លោកប៉ូលបន្ត និង ពណ៌នាអំពីស្ថានភាពរបស់យើងនៅក្នុងលោកិយ៍នេះ ថាដូចជាក្មេងខ្ចី ដែលជាខ្ញុំបំរើនៃ "អ្វីៗជាអរូប" ដែលមានឥទ្ធិពលលើលោកិយ៍ (មុនពេលព្រះយេស៊ូសុគត)។ អ្វីៗជាអរូបៈ "អ្វីៗដំបូង ដែលអ្វីផ្សេងទៀតជាកម្មសិទ្ធិទៅនឹងសេរីដូចគ្នា រឺ ធាតុទាំងមូល ជាអ្វីៗអរូបិយ រឺជាគោលការណ៍ដំបូង គេ" (Thayer) (សូមមើលកូឡូស ២:៨ ២:២០-២១ ហេប្រឺ ៥:១២ ២ពេត្រុស ៣:១០-១២)។ដូច្នេះ ក្រឹត្យ វិន័យមានលក្ខណៈអរូបិយ ឈឺចាប់ ឃោរឃៅ និង យុគសម័យ។ ច្បាប់ (វិន័យ) គឺជាកត្តាមូលដ្ឋាននៅក្នុងគ្រប់ សាសនាទាំងអស់។ វាសំរាប់ "កូនចៅ" ហើយវាក៏មិនបញ្ចប់ដោយឯកឯងដែរ។ ច្បាប់រំលឹកដល់មនសិការរបស់យើង នៅពេលដែលវាបង្ខំយើងអោយសំឡឹងមើលលើខ្លួនយើង។ ច្បាប់គឺជាធាតុនៃការមានជីវិតខាងវិញ្ញាណរបស់យើង។ លោកប៉ូលបន្តដោយនិយាយថា "លុះដល់ពេលកំណត់" ព្រះគ្រិស្តបានយាងមកនៅក្រោមក្រឹត្យវិន័យ ដើម្បីរំដោះអស់ អ្នកដែលស្ថិតនៅក្រោមក្រឹត្យវិន័យ។ ព្រះយេស៊ូបានប្រសូតមកក្នុងលោកិយ៍នេះ (នៅក្រោមក្រឹត្យវិន័យ) ប៉ុន្តែ ទ្រង់ នៅតែជាព្រះពេញលក្ខខណ្ឌ (ប្រសូតចេញពីស្ត្រីព្រហ្មចារី) មិនមែនជាមនុស្សដែលបានធ្លាក់ចុះ (ដូចជាពូជពង្សរបស់ លោកអប្រាហាំនោះទេ) ប៉ុន្តែ ទ្រង់ជាមនុស្សដែលគ្រប់លក្ខណ៍ (អដាំទីពីរ)។ ព្រះយេស៊ូបានរំដោះយើងចេញពី

បណ្តាសានៃក្រឹត្យវិន័យ ហើយបានប្រទានអោយយើងមានសិទ្ធិជា "កូនរបស់ព្រះ"។ នេះជាគំរោងផែនការរបស់ព្រះជាម្ចាស់ ដើម្បីអោយយើងក្លាយជាកូនពេញសិទ្ធិរបស់ព្រះជាម្ចាស់ ប៉ុន្តែ យើងមិនអាចទទួលសិទ្ធិនេះបានឡើយ រហូតទាល់តែព្រះគ្រិស្តបានបំពេញកិច្ចការរបស់ទ្រង់ជាមុនសិន។

នៅក្នុងខទី៦ យើងបានទទួលព្រះវិញ្ញាណរបស់ព្រះគ្រិស្ត (បុត្រារបស់ព្រះជាម្ចាស់ ជាបងប្អូនរបស់យើង)។ ឥឡូវនេះ យើងអាចហៅព្រះជាម្ចាស់ថាជាព្រះបិតារបស់យើងបានហើយ និង អ្វីមួយដែលយើងមិនអាចធ្វើនៅពីមុខព្រះគ្រិស្ត (សូមមើល ទំនុក ៦៨:៥ ៨៩:២៦ ១០៣:១៣)។ ការសង្គ្រោះធ្វើអោយព្រះជាម្ចាស់ក្លាយជាព្រះបិតារបស់យើង។ នៅក្នុងខទី៧ ដូច្នេះ យើងគឺជាបុត្ររបស់ព្រះជាម្ចាស់ មិនមែនជាខ្ញុំបំរើទៀតឡើយ ហើយយើងជាអ្នកទទួលកេរ្តិ៍មរតកតាមរយៈព្រះគ្រិស្ត។ ព្រះគ្រិស្តបានធ្វើអោយការអាចកើតឡើងបាន តាមរយៈការបំពេញតាមក្រឹត្យវិន័យ ដោយដោះយើងអោយមានសេរីភាពពីបណ្តាសានៃក្រឹត្យវិន័យ និង ចំណងនៃក្រឹត្យវិន័យ។ ព្រះអង្គប្រទានអោយយើងមានភ្នែកខាងវិញ្ញាណ ហើយឥឡូវនេះ យើងអាចជឿលើទ្រង់បាន។ ឥឡូវនេះ យើងជាអ្នកស្នងកេរ្តិ៍មរតករួមជាមួយទ្រង់។

នៅខទី៨ លោកប៉ូលមានប្រសាសន៍ថា កាលពីដើម អ្នកស្រុកកាឡាទីពុំស្គាល់ព្រះជាម្ចាស់ទេ។ ពួកគេធ្វើជាខ្ញុំបំរើរបស់ព្រះនានា ដែលមិនមែនជាព្រះដ៏ពិតប្រាកដ (ជាអ្វីៗដែលអរូបិយ៍នៅលើលោកិយ៍នេះ)។ ព្រះនានាដែលមិនមែនជាព្រះដ៏ពិតប្រាកដ: ក្បួនពិធី ការប្រព្រឹត្តតាមបញ្ញត្តិអារក្ស (សូមមើល ១កូរិន ៨:៥ ១០:២០) រឺ ការកែច្នៃគោលបំណងដើមនៃក្រឹត្យវិន័យ។ ទិដ្ឋភាពកែច្នៃក្រឹត្យវិន័យដើម (Mosaic រឺផ្សេងទៀត) គឺជាទិដ្ឋភាពដែលបង្ហាញថាខ្ញុំអាចសង្គ្រោះខ្លួនឯង អំពើល្អអាចសង្គ្រោះខ្ញុំបាន រឺតាមរយៈការចូលរួមក្បួនពិធីណាមួយ ។ល។ ពួកគេជាខ្ញុំបំរើរបស់ព្រះទាំងនោះ: ការធ្វើជាខ្ញុំបំរើមិនប្រាកដថា ជាការមួយអាក្រក់នោះទេ ដ្បិតអ្នកជឿក៏ជាខ្ញុំបំរើរបស់ព្រះគ្រិស្តផងដែរ ប៉ុន្តែ ការធ្វើជាខ្ញុំបំរើចៅហ្វាយអាក្រក់ រឺក៏រិតស្តង់ដាមួយដែលហួសហេតុពេក គឺជាបន្ទុកមួយដ៏ធ្ងន់ដែលត្រូវលី។

នៅក្នុងខទី៩ "តែឥឡូវនេះ បងប្អូនស្គាល់ព្រះជាម្ចាស់ បើនិយាយអោយចំ ព្រះអង្គបានស្គាល់បងប្អូនហើយ..." ទោះបីជាបន្ទាប់ពីបានស្គាល់ព្រះជាម្ចាស់ហើយក៏ដោយ ក៏អ្នកមិនស្គាល់ព្រះអង្គមិនច្បាស់ដែរ រីនឹងស្គាល់ទ្រង់ច្បាស់ឡើយ។ អ្នកស្គាល់ព្រះជាម្ចាស់តិចណាស់។ ការសង្គ្រោះកើតឡើង មិនចាំបាច់មានចំណេះដឹងអំពីព្រះជាម្ចាស់នោះទេ ប៉ុន្តែ ជាចំណេះដឹងអំពីព្រះជាម្ចាស់សំរាប់យើង គឺជាការដែលព្រះជាម្ចាស់បានស្គាល់យើង។ តើការដែលព្រះជាម្ចាស់បានស្គាល់យើងមានអត្ថន័យដូចម្តេច? (សូមមើល ២ធីម៉ូ ២:១៩ ១កូរិន ១៣:១២ ១កូរិន ៨:៣ រ៉ូម ៨:២៩ យ៉ូហាន ១០:១៤ ទំនុក ១:៦ និង និក្ខមនំ ៣៣:១៧។ ក្នុងភាសាយូដា ពាក្យថា "យ៉ាដា - yada" មានអត្ថន័យដូចទៅនឹងពាក្យជាភាសាក្រិកថា "ginosko"។ "Ginosko" គឺជាពាក្យមួយ ដែលគេប្រើនៅពេលដែលលោកប៉ូលសរសេរថា ព្រះជាម្ចាស់ "ស្គាល់" អ្នក។ "Yada" គឺជាពាក្យមួយដែលគេប្រើនៅក្នុងសម្ពន្ធមេត្រីចាស់ នៅពេលដែលមនុស្សម្នាក់ "ស្គាល់" ប្រពន្ធរបស់គាត់ គឺចង់សំដៅទៅលើការរួមភេទ។ ដូច្នេះ ព្រះតំរិះរបស់ព្រះជាម្ចាស់ចំពោះប្រជារាស្ត្ររបស់ទ្រង់ គឺជាចំណេះដឹងមួយដ៏ស្និទ្ធស្នាលស៊ីជំរៅខ្លាំងណាស់។

លោកប៉ូលសួរសំណួរថា: តែឥឡូវនេះ បងប្អូនស្គាល់ព្រះជាម្ចាស់ បើនិយាយអោយចំ ព្រះអង្គបានស្គាល់បងប្អូនហើយ ហេតុដូចម្តេចបានជាបងប្អូនបែរទៅជាខ្ញុំបំរើនឹងក្រឹត្យវិន័យ ដែលមិនអាចនឹងកាន់តាមទេវិញ (ស្ថិតក្រោមកម្លាំងផ្ទាល់របស់ខ្លួន) តើបងប្អូនដើរចេញពីភាពជាកូនព្រះជាម្ចាស់ហើយឬ? (ខទី៩) ហេតុដូចម្តេចបានជាបងប្អូនចង់បំរើអ្វីៗដែលមានឥទ្ធិពលដ៏ទន់ខ្សោយ (តូចតាច គ្មានតម្លៃ គ្មាននូវគុណធម៌នៃគ្រិស្តបរិស័ទ និង ភាពមានបានខាងក្រៅ ហើយគ្មានបារមីនឹងសំរេចទីចុងបញ្ចប់) និង គោលការណ៍ដ៏សាមញ្ញនៃលោកិយ៍នេះទេវិញ?

ខទី១០ "បងប្អូនគោរពថ្ងៃខែ..." (ម៉ាកុស ៣:២ រ៉ូម ១៤:៥-៦ កូឡូស ២:១៦)។ បងប្អូនដែលកាន់សាសនានោះបានគោរពថ្ងៃខែ គោរពរដូវ និង គោរពឆ្នាំ។ ពួកគេបានធ្វើបែបនេះ ដោយគិតថា ពួកគេកំពុងតែខិតខំដើម្បីទទួលការសង្គ្រោះ។ ព្រះជាម្ចាស់ចង់អោយយើងចងចាំអំពីពេល ដែលទ្រង់បានសង្គ្រោះ (យ៉ូស្វេ ៤:៥-៧) និង បាននាំយើងឆ្លងកាត់ទុក្ខលំបាក រឺបានផ្តល់អោយយើងនូវជ័យជំនះ ។ល។ ប៉ុន្តែ គោលបំណងដែលចងចាំពេលទាំងនោះ គឺ

ដើម្បីថ្វាយបង្គំព្រះជាម្ចាស់ មិនមែនទៅថ្វាយបង្គំដល់ការរំលឹកនោះទេ។ យើងមិនថ្វាយបង្គំអំណោយដែលមកពីព្រះជាម្ចាស់នោះទេ។ យើងមិនគោរពថ្ងៃខែឆ្នាំ បើទោះបីវាជាប្រភេទនៃគំរូវការសំរាប់ការសង្គ្រោះក៏ដោយ។

នៅក្នុងខទី១១ លោកប៉ូលពន្យល់ថា លោកបារម្ភសំរាប់អ្នកស្រុកកាឡាទី។ លោកបារម្ភថា ពួកគេមិនបានពិតជាជឿនោះទេ។លោកបារម្ភថា ពួកគេកំពុងតែរាថយក្រោយ (ហេប្រឺ ១០:៣៨ ហេប្រឺ ២:១-៣ [ខទី២ និយាយអំពីក្រឹត្យវិន័យ])។ លោកបារម្ភថា ពួកគេកំពុងតែត្រឡប់ទៅប្រព្រឹត្តតាមក្រឹត្យវិន័យ ហើយគ្រប់ការនឿយហត់ទាំងប៉ុន្មានរបស់លោក នឹងត្រឡប់ទៅជាឥតបានផលអ្វីទាំងអស់ (ឥតបានផល: ដោយគ្មានគោលបំណង ទទេស្អាត គ្មានតម្លៃ គ្មានប្រយោជន៍ គ្មានផលផ្លែ) (សូមមើល ១កូរិន ១៥:២)។ លោកប៉ូលអង្វរករអោយអ្នកស្រុកកាឡាទី (ខទី១២) សូមកាន់ចិត្តអោយបានដូចលោក: មានសេរីភាពពីក្រឹត្យវិន័យ និង ដូចជារូបលោកបានក្លាយដូចជាពួកគេ: សាសន៍ដទៃ។ លោកប៉ូលជាគណៈផារីស៊ីបានជំរុញ ដោយចិត្តខ្នះខ្នែងរបស់លោក ដើម្បីកាន់តាមក្រឹត្យវិន័យ ហើយលោកក៏ បានមានសេរីភាព (ដ្បិតសាសន៍យូដាលែងស្ថិតនៅក្រោមក្រឹត្យវិន័យទៀតហើយ)។ ពួកសាសន៍ដទៃទាំងនេះ (អ្នកស្រុកកាឡាទី) មិនដែលស្ថិតនៅក្រោមក្រឹត្យវិន័យរបស់សាសន៍យូដា។ បន្ទាប់ពីបានទទួលព្រះគ្រិស្តហើយ ពួកគេត្រូវបានបោកបញ្ឆោត ទៅស្ថិតនៅក្រោមក្រឹត្យវិន័យនេះវិញ។

លោកប៉ូលរំលឹកអ្នកស្រុកកាឡាទីអំពីភាពរាក់ទាក់ ដែលពួកគេបានទទួលលោកជាលើកដំបូង នៅពេលដែលលោកបានមកជួបពួកគេជាលើកទីមួយ (ខទី១៣-១៤)។ លោករំលឹកពួកគេថា ពួកគេបានបែរភ្នែកចេញពីលោក។ ប៉ុន្តែ ឥឡូវនេះ ពួកគេឃើញលោកប៉ូលជាសត្រូវទៅវិញ។ ខទី១៧ ចែងថា: "ពួកគេខំប្រឹងផ្តាច់ផ្តន់បងប្អូន"។ នៅពេលដែល លោកប៉ូលមកជួបអ្នកស្រុកកាឡាទីជាលើកដំបូង លោកបានមកដោយមានសុខភាពទន់ខ្សោយ ប៉ុន្តែ លោកបានមក ជាមួយនឹងសេចក្តីពិត។ ក្រោយមក ពួកសាសន៍យូដាបានមកដោយចិត្តខ្នះខ្នែង ហើយពួកគេបានប្រើកម្លាំងរបស់ពួកគេ ដើម្បីបោកបញ្ឆោតអ្នកស្រុកកាឡាទី។ សូមស្រមៃពីអ្វីដែលពួកសាសន៍យូដានិយាយអំពីលោកប៉ូល នៅពេលដែលលោក មិននៅជិត។

ពួកគេប្រាកដជានិយាយថា លោកប៉ូលកំពុងតែបោះបង់ចោលអ្នកស្រុកកាឡាទី ពីព្រោះថា លោកមិនបានបង្រៀនពួកគេអោយគោរពតាមក្រឹត្យវិន័យ។ ប្រសិនបើពួកគេជឿថា លោកប៉ូលកំពុងតែចង់បោះបង់ចោលពួកគេ នោះពួកគេនឹងត្រឡប់ទៅកាន់តាមអ្វីៗជាអរូបិយ៍ គឺ "ការសង្គ្រោះខ្លួនឯង/ឯករាជ្យ" ដែលជាអ្វីៗនៃលោកិយ៍នេះ។ ដូចជានៅក្នុងសួនអញ្ជឹង នៅពេលដែលសាតាំងធ្វើអោយអដាំ និង អេវ៉ាគិតថា ព្រះជាម្ចាស់បដិសេធចោលពួកគេ និង ធ្វើអោយពួកគេស្វែងរកជីវិតឯករាជ្យ ដូច្នេះ អ្នកស្រុកកាឡាទីកំពុងតែស្វែងរកភាពឯករាជ្យពីជំនឿនៅក្នុងព្រះគ្រិស្ត។

នៅក្នុងខទី១៨ លោកប៉ូលមានប្រសាសន៍ថា ការយកចិត្តទុកដាក់ដោយមានគោលបំណងល្អគ្រប់ពេលវេលានោះជាការត្រឹមត្រូវហើយ។មនុស្សដែលមកដោយមានហេតុផលត្រឹមត្រូវ នឹងមិនដែលជាបន្ទុកនោះទេ ដ្បិតពួកគេមានសេចក្ដីពិត ហើយពួកគេចង់ចែកចាយសេចក្ដីពិតនោះ។ អស់អ្នកដែលមកដោយមានហេតុផលខុសឆ្គង គឺជាបន្ទុក និង ជាបញ្ហា ដ្បិតពួកគេមកដើម្បីធ្វើអោយខូចដល់សេចក្ដីពិត។ ពួកគេមកដោយមានហេតុផលអាត្មានិយម។

នៅក្នុងខទី១៩ គឺជាខមួយគួរអោយចាប់អារម្មណ៍ លោកប៉ូលមានប្រសាសន៍ថា "ខ្ញុំឈឺចាប់ក្នុងការបង្កើតអ្នករាល់គ្នាសាជាថ្មី" និង "រហូតទាល់តែព្រះគ្រិស្តបានកើតជារូបរាងឡើងក្នុងអ្នករាល់គ្នា។" (ភីលីព ២:១២) និង នៅក្នុងខទី២០ "ខ្ញុំទ័លគំនិត មិនដឹងជាត្រូវសរសេរយ៉ាងដូចម្ដេចមកបងប្អូនទេ"។ លោកប៉ូលបានសង្ស័យលើការសង្គ្រោះរបស់អ្នកស្រុកកាឡាទី។

នៅក្នុងខទី២១ លោកប៉ូលបន្តទៀតថា "បងប្អូនដែលជាអ្នកចង់ចុះចូលនឹងក្រឹត្យវិន័យអើយ..." លោកចង់អោយពួកគេគិតអំពីអ្វីដែលពួកគេកំពុងតែធ្វើ អោយពួកគេស្វែងយល់អោយបានច្បាស់អំពីក្រឹត្យវិន័យ។ នៅក្នុងខទី២២ អប្រាហាំមានកូនប្រុសពីរនាក់: ម្នាក់កើតចេញពីស្ត្រីអ្នកងារ ហើយម្នាក់ទៀតកើតចេញពីស្ត្រីអ្នកជា (លោកុប ១៦:២-៤ ១៦:១៥ ២១:១-២ ២១:១០)។លោកប៉ូលពន្យល់ដោយការប្រៀបធៀបរវាងក្រឹត្យវិន័យ និង ជំនឿ: ស្ត្រីអ្នកជា និងស្ត្រីអ្នកងារ ព្រះបន្ទូលសន្យា និង ក្រឹត្យវិន័យ ជំនឿ និង ក្រឹត្យវិន័យ ព្រះគ្រិស្ត និង ម៉ូសេ ព្រះគ្រិស្ត និង អដាំ

និស្ស័យថ្មី និង និស្ស័យចាស់ ដួងចិត្តនៃសាច់ឈាម (កើតជាថ្មី) និង ដួងចិត្តនៃសិលា វិញ្ញាណ និង សាច់ឈាម (ធ្លាក់ចុះ)។ លោកប៉ូលប្រៀបធៀបនាងហាការ (ជាម្តាយមួយប្រភេទ) ទៅនឹងសម្ពន្ធមេត្រីដែលចងនៅភ្នំស៊ីណៃ និង ជានិមិត្តរូបនៃក្រុងយេរូសាឡឹមសព្វថ្ងៃនេះ (ព្រះវិហារ និង ភាពជាបូជាចារ្យម៉ូសេ) ប៉ុន្តែ ម្តាយជាអ្នកជាវិញ គឺជាតំណាងអោយក្រុងយេរូសាឡឹមនៅស្ថានលើវិញ (សូមមើល វិវរណៈ ២១:១០-២៧) (សេរីភាពៈ យ៉ូហាន ៨:៣៦ រ៉ូម ៦:១៤ ៦:១៨ ១ពេត្រុស ២:១៦)។ លោកប៉ូលដកស្រង់ចេញពីអេសាយ ៥៤:១ នៅក្នុងខទី២៧ ដើម្បីបង្ហាញពីរបៀបដែលស្ត្រីអារ (អ្នកស្រីសារ៉ា) បានទទួលពរដ៏លើសលប់ ដ្បិតនាងនឹងក្លាយជាម្តាយនៃកូននៃព្រះបន្ទូលសន្យា។ នៅក្នុងខទី២៩-៣០ លោកប៉ូលនិយាយអំពីរបៀបដែលកូននៃសាច់ឈាមបៀតបៀនកូននៃព្រះបន្ទូលសន្យា ប៉ុន្តែ បន្ទាប់មក លោកបានដកស្រង់ចេញពីលោកុប្បត្តិ ២១:១០ ដើម្បីបង្ហាញពីជោគវាសនានៃកូននៃសាច់ឈាមៈ ពួកគេនឹងត្រូវបណ្តេញចេញ (លូកា ១៣:២៨ យេរេមា ១៥:១-២ អេសេគាល ១៥:២-៥)។ យើងរាល់គ្នាដែលជាកម្មសិទ្ធិរបស់ព្រះគ្រិស្ត គឺជាកូននៃស្ត្រីជា (យ៉ូហាន ៦:៣៧)

**ជំពូកទីប្រាំ**

នៅក្នុងខទី១ "ព្រះគ្រិស្តបានរំដោះយើងអោយមានសេរីភាពពិតប្រាកដ។" តើវាមាននូវហេតុផលអ្វីផ្សេងទៀតដែររឺអត់? (អេសាយ ៦១:១) ដូច្នេះ ហេតុអ្វីបានជាមនុស្សគ្រប់គ្នាបែរទៅជាខ្ញុំបំរើគេទៅវិញ? ព្រះគ្រិស្តមិនបានសុគត ដើម្បីអោយយើងអាចសង្គ្រោះខ្លួនយើង ដោយភាពជោគជ័យច្រើនជាងពេលដែលទ្រង់សុគតនោះទេ។ ទ្រង់បានសុគតដើម្បីសង្គ្រោះយើង គឺទ្រង់បានសុគតសំរាប់យើង។ ពាក្យថា "សេរីភាព" ដែលប្រើនៅក្នុងខគម្ពីរនេះមានអត្ថន័យជាភាសាក្រិកថាៈ "ជាសេរីភាព ដើម្បីធ្វើ រឺលុបចោលនូវអ្វីៗដែលគ្មានទំនាក់ទំនងទៅនឹងការសង្គ្រោះ។" ដូច្នេះ វាមានន័យថា ខ្ញុំមិនត្រូវកាន់តាមក្រឹត្យវិន័យទាំងឡាយណាដែលមិនចាំបាច់នោះទេ ប៉ុន្តែ ខ្ញុំក៏អាចរស់នៅក្នុងជីវិតមួយដ៏វិសុទ្ធបាន និង មានសេរីភាពពីការតយុទ្ធនៃបំណងឆន្ទៈ។ ក្រឹត្យវិន័យនៃលោកម៉ូសេ ជាកម្លាំងខាងក្រៅដែលកំពុងតែប្រហារឆន្ទៈរបស់ខ្ញុំនោះ ត្រូវបានជំនួសដោយ "ការផ្លាស់ប្រែ" ផ្នែកខាងក្នុងវិញ។ "ការផ្លាស់ប្រែ" នេះ ត្រូវតែខំប្រឹងធ្វើការ "ទាំងគោរពកោតខ្លាច និង ញាប់ញ័រ" (ភីលីព ២:១២)

លោកប៉ូលបន្តដោយមានប្រសាសន៍ថា: កុំបណ្តោយខ្លួនធ្លាក់ទៅតាមការសង្គ្រោះ "ដោយខ្លួនឯង" តាមពួកផារីស៊ីនោះឡើយ។ ខទី២ លោកប៉ូលព្រមានថា បើបងប្អូនទទួលពិធីកាត់ស្បែកនោះ ព្រះគ្រិស្តលែងមានប្រយោជន៍អ្វីដល់បងប្អូនទៀតហើយ។ នេះមានន័យថា គ្មានការសង្គ្រោះចេញពីព្រះយេស៊ូទៀតទេ។ វាមានអត្ថន័យថា ពិធីកាត់ស្បែកមានអត្ថន័យលើសពីការគ្រាន់តែកាត់ស្បែកធម្មតាទៅទៀត។ វាចង់សំដៅថា ពួកគេបានបដិសេធចោល "ការសង្គ្រោះដែលទទួលបានតាមរយៈព្រះគុណ និង ជំនឿ" ដែលលោកប៉ូលបានបង្រៀនពួកគេពីដំបូង។ ដូច្នេះ វាគ្មានអ្វីគួរអោយឆ្ងល់ឡើយ ដែលលោកប៉ូលមានមន្ទិលថា ពួកគេទាំងនេះពិតជាបានទទួលការសង្គ្រោះនោះ ដ្បិត មនុស្សដែលកើតជាថ្មីពិតៗ នឹងមិនបដិសេធសេចក្តីពិតឡើយ។ រឺ វាលុះត្រាតែពួកគេមិនយល់ទាល់តែសោះ។

នៅក្នុងខទី៣ លោកប៉ូលមានប្រសាសន៍ថា អស់អ្នកដែលទទួលពិធីកាត់ស្បែកក្លាយជាកូនបំណុលទៅនឹងក្រឹត្យវិន័យទាំងមូល។ ភាសាក្រិកចែងថា កូនបំណុលគឺជា "ម្នាក់ដែលមិនទាន់សងការប៉ះប៉ូវដល់អ្នកដែលគាត់បានធ្វើអោយរងរបួស។" អស់អ្នកដែលបានប្រព្រឹត្តអំពើបាបអ្នកនោះប្រឆាំងទាស់នឹងព្រះជាម្ចាស់ និង ក្រឹត្យវិន័យរបស់ទ្រង់ (ទំនុក ៥១:៤)។ ក្រឹត្យវិន័យអាចបញ្ជាដល់អស់អ្នកដែលជាអ្នកកាន់តាមក្រឹត្យវិន័យ។ ក្រឹត្យវិន័យ (ច្បាប់) គ្មានមេត្តា ឡើយ ពីព្រោះថា ច្បាប់គឺជាច្បាប់។ វាគ្មានសេចក្តីមេត្តាករុណានោះឡើយ។វាចេញបញ្ជា ដោយគ្មានចិត្តទន់ឡើយ ហើយវាមិនគួរមានចិត្តទន់ដែរ ដ្បិតវានឹងមិនធ្វើអោយព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ (សុភាសិត ១៧:១៥)។ ដូច្នេះ វាជាជម្រើសមួយកាន់តែអាក្រក់ទៅទៀតហើយ។

នៅក្នុងទី៤ លោកប៉ូលសរសេរថា: បងប្អូនបាន "បែកចេញ" ពីព្រះគ្រិស្តហើយ។ ការបកប្រែម្យ៉ាងទៀតចែងថា ប្រិតប្រៀន។ អត្ថន័យជាភាសាក្រិកគឺ: "ធ្វើអោយគ្មានន័យ" រឺ "ធ្វើអោយនរណាម្នាក់ទៅជាគ្មានកម្លាំង" (Thayer and Strong's)។ "បើបងប្អូនចង់បានសុចរិត ដោយពឹងផ្អែកលើក្រឹត្យវិន័យ នោះបងប្អូនដាច់ចេញពីព្រះគុណហើយ"។ ព្រះគុណ: ផ្តល់នូវអំណោយ សេចក្តីអនុគ្រោះ សេចក្តីរីករាយ ភាពផ្អែមល្ហែម មន្តស្នេហ៍ ភាពគួរអោយស្រឡាញ់ ពាក្យ

ពេចន៍សមគួរ អារម្មណ៍រួសរាយរាក់ទាក់ ចិត្តសប្បុរស និង យោគយល់។" (Thayer) ព្រះគុណៈ "ជាសេចក្តីមេត្តាករុណាមកពីព្រះជាម្ចាស់ ដោយប្រើនូវឥទ្ធិពលដ៏វិសុទ្ធរបស់ទ្រង់មកលើព្រលឹងមនុស្សអោយបែរទៅរកព្រះគ្រិស្ត និង រក្សា ពង្រឹង បង្កើនព្រលឹងទាំងនោះនៅក្នុងជំនឿគ្រិស្តបរិស័ទ ចំណេះដឹង សេចក្តីស្រឡាញ់ និង បញ្ឆេះពួកគេអោយប្រតិបត្តិតាមគុណធម៌របស់គ្រិស្តបរិស័ទ។" (Thayer) ព្រះគុណៈ "...ជាឥទ្ធិពលរបស់ព្រះជាម្ចាស់មកលើចិត្ត និង ជាការឆ្លុះបញ្ចាំងនៅក្នុងជីវិត ហើយវារួមទាំងចិត្តដឹងគុណ..." (Strong's) ដូច្នេះ ការបែកចេញពីព្រះគុណគឺជាការបែកចេញពីព្រះជាម្ចាស់ ដ្បិតទ្រង់ជាព្រះដែលបំផ្លាស់អ្នកអោយទៅជាមនុស្សមួយថ្មី ដោយមាននិស្ស័យថ្មី។ ការដែលមិនទុកចិត្តលើព្រះគ្រិស្តសំរាប់ការសង្រ្គោះ វាន័យថាអ្នករស់នៅស្ថិតក្រោមក្រឹត្យវិន័យ ជាជាងរស់នៅក្រោមព្រះគុណហើយ (សូមមើលរ៉ូម ១១:៦ ហេប្រឺ ៦:៤-៦ ហេប្រឺ ១០:៣៨-៣៩ ហេប្រឺ ១២:១៥ ២ពេត្រុស ២:២០-២២ ២ពេត្រុស ៣:១៧-១៨ វិវរណៈ ២:៥)។

នៅក្នុងខទី៥ និង ទី៦ ចែងថា ជំនឿដំណើរការតាមរយៈសេចក្តីស្រឡាញ់ (សូមមើល ១យ៉ូហាន ៤:១៨-២១ ១យ៉ូហាន ៣:១៩-២០ ១ពេត្រុស ១:៨)។ យើងទន្ទឹងរង់ចាំក្តីសង្ឃឹមនៃសេចក្តីសុចរិតៈ ជាខណៈពេលចុងក្រោយនៃជីវិតរបស់យើង នៅពេលដែលយើងពិតជាមានសេរីភាពទាំងស្រុងពីអំពើបាប។ ពិធីកាត់ស្បែកមិនសំខាន់អ្វីឡើយ ដ្បិតឥឡូវនេះ យើងមានជំនឿដែលនាំអោយប្រព្រឹត្តអំពើផ្សេងៗ ដោយចិត្តស្រឡាញ់ប៉ុណ្ណោះទើបសំខាន់។ (សូមមើល ១ថេស្សា ២:១៣ រ៉ូម ៧:៥ ២កូរិន ១:៦ ២កូរិន ៤:១២ ២ថេស្សា ២:៧ អេភេ ៣:២០)។

ខទី៧-៩ លោកប៉ូលមានអារម្មណ៍អន់ចិត្តចំពោះអ្នកស្រុកកាឡាទី ដ្បិតពួកគេបានចាប់ផ្តើមជំនឿរបស់ពួកគេល្អណាស់ ប៉ុន្តែ ក្រោយមក ពួកគេបានឈប់ទៅវិញ។ លោកហាក់ដូចជាមានអារម្មណ៍ភ្ញាក់ផ្អើល ដែលពួកគេថែមទាំងចង់បែរចេញទាំងស្រុងតែម្តង។ លោកសួរពួកគេថាៈ "តើនរណារារាំងបងប្អូនមិនអោយស្តាប់បង្គាប់សេចក្តីពិតដូច្នេះ?" នៅក្នុងខទី១០ លោកប៉ូលសន្និដ្ឋានថា ពួកគេមិនទាន់ទទួលយកការបង្រៀនផ្សេងទៀត ដែលខុសពីអ្វីដែលលោកបានបង្រៀនពួកគេនៅឡើយទេ។ លោកជឿថា ព្រះជាម្ចាស់នឹងមិនអនុញ្ញាតអោយពួកគេបែកចេញពីទ្រង់ឡើយ ប៉ុន្តែទ្រង់នឹងដាក់ទោសដល់អ្នកដែលធ្វើខុស។ លោកប៉ូលព្រមានដល់មនុស្សទាំងអស់អោយដើរតាមផ្លូវដ៏ត្រឹមត្រូវវិញ។

នៅក្នុងខទី១១ លោកប៉ូលចង់អោយអ្នកស្រុកកាឡាទីគិតពិចារណាអំពីអ្វីដែលពួកគេកំពុងតែធ្វើ។ ប្រសិនបើលោកប៉ូលបានប្រកាសអោយធ្វើពិធីកាត់ស្បែក នោះលោកនឹងមិនត្រូវបៀតបៀនដោយពួកសាសន៍យូដាឡើយ ពីព្រោះថា នេះគឺជាអ្វីដែលពួកគេចង់បាន។ ហេតុអ្វីបានត្រូវប្រកាសអំពីឈើឆ្កាងទៀត ប្រសិនបើ ពិធីកាត់ស្បែកអាចសង្គ្រោះពួកគេបានហើយនោះ? នៅក្នុងខទី១២ លោកប៉ូលមានអារម្មណ៍អន់ចិត្តយ៉ាងខ្លាំង ហើយមានប្រសាសន៍ថា: "ខ្ញុំសូមអោយអ្នកដែលនាំអោយបងប្អូនជ្រួលច្របល់បែបនេះ ត្រូវគេក្រៀវខ្លួនតែម្តងទៅ។" ពិធីកាត់ស្បែកអាចប្រើប្រាស់ដោយត្រឹមត្រូវ បាន ដោយអស់អ្នកដែលយល់ពីទំនាក់ទំនងរបស់វាជាមួយនឹងការសង្គ្រោះដែលបានមកតាមរយៈជំនឿ និង ការស្តាប់បង្គាប់ព្រះជាម្ចាស់ (លោកុប្ប ១៧:១១ ទុតិយ ១០:១៦ ទុតិយ ៣០:៦ យេរេ ៤:៤ យេរេ ៩:២៥-២៦ ភីលីព ៣:៣)។

ខទី១៣ លោកប៉ូលពន្យល់ថា ពួកគេមានសេរីភាពពីផ្នត់គំនិត "ខ្លួនអាចសង្គ្រោះខ្លួនឯង" ប៉ុន្តែ លោកបានព្រមានពួកគេថា ពួកគេមិនត្រូវប្រើសេរីភាពនេះ មកធ្វើជាលេស ដើម្បីរស់នៅតាមនិស្ស័យលោកីយ៍នោះឡើយ។ លោកប្រាប់ពួកគេអោយចេះបំរើគ្នាទៅវិញទៅមកដោយចិត្តស្រឡាញ់។ នេះធ្វើតាមបទបញ្ជារបស់ព្រះយេស៊ូ ដ្បិតទ្រង់មានព្រះបន្ទូលអោយយើងចេះស្រឡាញ់គ្នាទៅវិញទៅមក (ជាបទបញ្ជាដ៏ធំសំខាន់បំផុត: ស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់គ្នាទៅវិញទៅមក (ម៉ាថាយ ២២:៣៧-៤០)។បទបញ្ជាទាំងពីរនេះគឺជាឫសគល់របស់គម្ពីរវិន័យ និង គម្ពីរព្យាការីទាំងអស់។ដូច្នេះ សេរីភាពរបស់យើងដោះយើងពី "ចិត្តគំនិតនៃការសង្គ្រោះខ្លួនឯង" និង ផ្តល់សេរីភាពអោយយើងស្រឡាញ់ព្រះជាម្ចាស់ និង អ្នកដទៃទៀត ដែលយើងគួរតែធ្វើ។ ដូច្នេះ សេរីភាពដ៏ពិតកើតមានឡើងនៅពេលដែលយើងមានសេរីភាពពីខ្លួនយើង: គឺរស់នៅដោយមិនមានចិត្តអត្តានិយម និង រស់នៅសំរាប់ព្រះជាម្ចាស់ និង អ្នកដទៃទៀត។ អស់អ្នកដែលមានសមត្ថភាពអាចធ្វើបែបនេះបាន គឺជាអ្នកដែលមានសេរីភាពដ៏ពិត មានឫទ្ធានុភាពដ៏ពិត និង មានតែព្រះជាម្ចាស់តែមួយគត់ដែលគ្រប់គ្រងជីវិតរបស់គាត់។ ព្រះយេស៊ូអាចរស់នៅបែបនេះបានដែលស្ថិតនៅក្រោមព្រះចេស្តារបស់ទ្រង់ផ្ទាល់ ដូច្នេះ យើងត្រូវតែរស់នៅបែបនេះ ដោយពឹងអាងលើព្រះចេស្តារបស់

ព្រះយេស៊ូ មិនមែនកម្លាំងរបស់យើងនោះឡើយ។ ក្រិត្យវិន័យទាំងមូលអាចសំរេចបាន តាមរយៈការដែលយើងចេះស្រឡាញ់គ្នាទៅវិញទៅមក (ខទី១៤)។

ខទី១៥គឺជាខមួយគួរអោយចាប់អារម្មណ៍។ ប្រហែលជាលោកប៉ូលកំពុងតែនិយាយថា: "ប្រសិនបើបងប្អូនមិនអាចស្រឡាញ់គ្នាទៅវិញទៅមក (បែកបាក់គ្នាដោយសារតែគោលលទ្ធិ) ដូច្នេះ ចូរប្រយ័ត្នមិនត្រូវបំផ្លាញគ្នាទៅវិញទៅមក។ ពាក្យថា "consume" មានន័យថា ប្រើអស់ ឬបំផ្លាញ។តាមពិតទៅ សកម្មភាពបែបនេះមិនគួរកើតមាននៅកន្លែងដំបូងគេឡើយ។ តើលោកប៉ូលគិតយ៉ាងដូចម្តេច បើលោកបានឃើញពីស្ថានភាពនយោបាយនៃក្រុមជំនុំនាពេលបច្ចុប្បន្ននេះ?

ក្នុងខទី១៦ លោកប៉ូលប្រាប់ពួកគេអោយរស់នៅស្របតាមព្រះវិញ្ញាណ (សូមមើល រ៉ូម ៨:៤-៥)។ ខទី១៧ "ដ្បិតបំណងលោភលន់របស់និស្ស័យលោកីយ៍ តែងតែទាស់នឹងព្រះវិញ្ញាណ ហើយព្រះវិញ្ញាណក៏មានបំណងទាស់នឹងនិស្ស័យលោកីយ៍ដែរ។ និស្ស័យលោកីយ៍ និង ព្រះវិញ្ញាណតែងតែផ្ទុយគ្នាទាំងស្រុង ដូច្នេះ បងប្អូនពុំអាចធ្វើអ្វី ដែលបងប្អូនចង់ធ្វើនោះបានឡើយ។" បំណងនៃសាច់ឈាម (បំណងលោភលន់របស់និស្ស័យលោកីយ៍) គឺទៅធ្វើការអាក្រក់ ប៉ុន្តែបំណងរបស់ព្រះវិញ្ញាណវិញ គឺធ្វើអ្វីដែលល្អ។ ប្រសិនបើខ្ញុំដើរតាមបំណងសាច់ឈាម លទ្ធផលចុងបញ្ចប់គឺជាការអាក្រក់មិនខាន ព្រោះវាគឺជាបំណងនៃសាច់ឈាម ហើយបំណងនៃសាច់ឈាមនឹងមិនដែលមានការល្អកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំឡើយ។ ប៉ុន្តែ ការដើរតាមព្រះវិញ្ញាណនឹងតែងតែបង្កើតនូវផលល្អជានិច្ច។ បំណងនៃសាច់ឈាមនឹងមិនដែល ឬមិនអាចគ្រប់គ្រងលើជីវិតរបស់ខ្ញុំបានឡើយ ដរាបណាខ្ញុំដើរតាមបំណងនៃព្រះវិញ្ញាណ។ ដូច្នេះ ដរាបណាខ្ញុំដើរដោយព្រះវិញ្ញាណ ក្រិត្យវិន័យនឹងមិនអាចថ្កោលទោសខ្ញុំបានឡើយ ដ្បិតក្រិត្យវិន័យកំពុងតែធ្វើការនៅក្នុងខ្ញុំ បង្កើតនូវលទ្ធផលល្អ ប៉ុន្តែ ប្រសិនបើខ្ញុំដើរតាមបំណងសាច់ឈាមវិញ នោះក្រិត្យវិន័យដែលស្ថិតនៅខាងក្រៅខ្ញុំ បង្កើតជាការថ្កោលទោស។ ក្រិត្យវិន័យតែមួយមិនអាចធ្វើអ្វីបានទាំងអស់។ ជីវិតរបស់ខ្ញុំផ្លាស់ប្រែទាក់ទងនឹងក្រិត្យវិន័យ (ខ១៨)។ ទំនាក់ទំនងរបស់ខ្ញុំទៅនឹងក្រិត្យវិន័យ (យេរេ ៣១:៣១-៣៣) អាចផ្លាស់ប្រែបាន

ដោយសារតែអ្វីដែលព្រះគ្រិស្តបានធ្វើនៅលើឈើឆ្កាងតែមួយគត់ (ហេប្រើ ៩:១៥)។ ខទី១៩-២១ រៀបរាប់ពីផលផ្លែនៃសាច់ឈាម ហើយពីខទី២២-២៤ រៀបរាប់ពីផលផ្លែនៃព្រះវិញ្ញាណ ដូច្នេះ វាលែងមានការយល់ច្រលំគ្នាទៀតហើយ ដែលថានរណាម្នាក់ជាអ្នកបំរើរបស់ព្រះគ្រិស្ត (ដើរតាមព្រះវិញ្ញាណ) រឺ មិនមែននោះ (ដើរតាមសាច់ឈាម) (ម៉ាថាយ ៧:១៦-២៧)។ ខទី២៥: ប្រសិនបើយើងមានជីវិត ដោយសារព្រះវិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ។

ខទី២៦: ចូរធ្វើគ្រប់កិច្ចការទាំងអស់ ដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់ មិនមែនដើម្បីអោយគេលើកតម្កើងខ្លួន គោលលទ្ធិរបស់ខ្លួន ក្រុមរបស់ខ្លួន រឺ ក៏សំរាប់កេរ្តិ៍ឈ្មោះនៃអង្គភាពរបស់អ្នកនោះឡើយ។ (សូមមើលខទី១៥)

**ជំពូកទីប្រាំមួយ**

ខទី១ លោកប៉ូលលើកឡើងថា ប្រសិនបើបងប្អូនណាម្នាក់ត្រូវគេទាន់នៅពេលកំពុងតែធ្វើអំពើអាក្រក់ណាមួយ បងប្អូនដែលមានព្រះវិញ្ញាណនៅក្នុងខនត្រូវកែតំរង់អ្នកនោះ ដោយចិត្តស្លូតបូត។ មនុស្សដែលមានព្រះវិញ្ញាណស្គាល់យ៉ាងច្បាស់ពីលក្ខណ:របស់អ្នកដែលមានព្រះគ្រិស្ត និង អ្នកដែលគ្មានព្រះគ្រិស្ត។ ពួកគេស្គាល់ពីលក្ខណ:ពិតរបស់ពួកគេ ដែលពាក់ពិននឹងការសង្គ្រោះ និង មិនពាក់ពិននឹងការសង្គ្រោះ។ ប្រសិនបើខ្ញុំមិនយល់ពីភាពពឹងអាងទាំងស្រុងទៅលើព្រះគ្រិស្តសំរាប់ការសង្គ្រោះទេ នោះខ្ញុំមិនគួរជាម្នាក់ដែលស្តីបន្ទោសបងប្អូនរួមជំនឿដទៃទៀត ដែលធ្វើខុសនោះទេ។វាពិតជាឃោរឃៅណាស់ ប្រសិនបើខ្ញុំគិតថាចំណុចខ្លាំងរបស់ខ្ញុំដើរតួយ៉ាងសំខាន់នៅក្នុងការសង្គ្រោះរបស់ខ្ញុំនោះ។ បងប្អូនគួរតែប្រុងប្រយ័ត្ន ក្រែងលោបងប្អូនមានអំណួត នៅពេលដែលបងប្អូនស្តីបន្ទោសអ្នកដទៃ។ ខទី២-៣ យើងត្រូវជួយទុក្ខធុរ:គ្នាទៅវិញទៅមក ដោយមិនវាយឫកខ្ពស់ និង គិតថាខ្លួនជាមនុស្សសំខាន់ខ្លាំងពេក។ ប្រសិនបើអ្នកឃើញបងប្អូនរួមជំនឿដទៃទៀតប្រព្រឹត្តអំពើបាប អ្នកគួរតែចូលទៅរក និង ជួយទុក្ខធុរ:របស់ពួកគេ។ មិនត្រូវគិតថា ពួកគេជាគូប្រកួតប្រជែងរបស់អ្នក ដើម្បីធ្វើអោយព្រះជាម្ចាស់គាប់ព្រះហឫទ័យនោះទេ។ ខទី៤-៥ ចែងថា ម្នាក់ៗត្រូវតែធ្វើការងាររបស់ខ្លួន ដោយសច្ចភាព និង ភាពល្អឥតខ្ចោះ។ មនុស្សម្នាក់ៗនឹងទទួលការកាត់ទោស

ស្របតាមរបៀបដែលពួកគេប្រើប្រាស់បន្ទុក ដែលពួកគេទទួលបាននៅក្នុងក្រុមជំនុំ ក៏ដូចជាផ្នែកផ្សេងទៀត។ យើងគឺសរីរាង្គគ្នាទៅវិញទៅមកនៅពេលដែលបំពេញតួនាទីរបស់យើងនៅក្នុងក្រុមជំនុំ ប៉ុន្តែ ក្នុងនាមយើងជាសរីរាង្គ យើងមិនមែនជាក្រុមជំនុំទេ គឺយើងធ្វើការជាមួយគ្នាជាអង្គតែមួយ ដើម្បីគាំទ្រគ្នាទៅវិញទៅមក ហើយម្នាក់ៗនឹងទទួលចំណែករៀងៗខ្លួន ដើម្បីបង្កើតនូវព្រះកាយនៃក្រុមជំនុំ គឺមានចិត្តគំនិតតែមួយនៅក្នុងព្រះកាយព្រះគ្រិស្ត។ ខទី៦ ចំពោះអស់អ្នកដែលទទួលការអប់រំខាងព្រះបន្ទូល ត្រូវយកអ្វីទាំងប៉ុន្មានដែលខ្លួនមានមួយចំណែក មកចែកដល់អ្នកដែលអប់រំខ្លួននោះផង។

នៅក្នុងខទី៧-១០ និយាយអំពីការសាបព្រោះ និង ការទទួលផល។ សាបព្រោះតាមនិស្ស័យលោកីយ៍: ទទួលផលខាងលោកីយ៍ (ភាពពុករលួយ: ដែលស្អុយរលួយ ជាអ្វីដែលត្រូវបំផ្លាញចោល) តែបើសាបព្រោះខាងព្រះវិញ្ញាណវិញ: ទទួលផលខាងព្រះវិញ្ញាណ (ជីវិតដ៏អស់កល្ប: គ្មានទីបញ្ចប់ និង គ្រប់លក្ខណ៍)។ លោកប៉ូលមានប្រសាសន៍ថា: "មិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់ យើងនឹងច្រូតបានផលជាមិនខាន។" យើងត្រូវតែប្រើប្រាស់ឱកាសរបស់យើង ដើម្បីធ្វើអំពើល្អ នៅពេលដែលយើងអាចធ្វើបានជាពិសេស ចំពោះបងប្អូនរួមជំនឿរបស់យើង។

ខទី១១ លោកប៉ូលបង្ហាញម្តងទៀតអំពីសារសំខាន់នៃអ្វីដែលលោកកំពុងតែសរសេរ: "ជាអក្សរធំ"។ ខទី១២-១៣ លោកប៉ូលមានប្រសាសន៍ថា: "ពួកអ្នកដែលបានទទួលពិធីកាត់ស្បែក" មិនចង់ទទួលការបៀតបៀន ព្រោះតែព្រះគ្រិស្ត ដូច្នេះ ពួកគេដើរចេញពីព្រះគុណរបស់ព្រះជាម្ចាស់ ហើយបង្ខំបងប្អូនដែលបានសង្គ្រោះអោយធ្វើតាមវិន័យវិញ។ខទី១៣ចែងថា ចំពោះអ្នកដែលកាត់ស្បែកទាំងនោះ ខ្លួនគេផ្ទាល់ពុំកាន់តាមក្រឹត្យវិន័យទេ។ ពួកគេជាមនុស្សមាន ពុតត្បុត។ ពួកគេចង់អួតក្អេងក្អាងថា ពួកគេមានអំណាចត្រួតត្រាលើគ្រិស្តបរិស័ទ ពីព្រោះពួកគេបានទាក់ទាញបងប្អូន ទាំងនោះអោយធ្វើពិធីកាត់ស្បែក។ ចំណែកឯលោកប៉ូលវិញ លោកអួតអាងអំពីឈើឆ្កាងរបស់ព្រះយេស៊ូគ្រិស្ត (ខទី១៤)។

ព្រះចេស្ដាដ៏ពិតនៃការសង្គ្រោះមាននៅក្នុងព្រះគ្រិស្ដ បើទោះបីជាអ្នកត្រូវបានកាត់ស្បែកក្ដី រឺមិនបានកាត់ស្បែកក្ដី។ដូច្នេះ អស់អ្នកដែលរស់នៅស្របតាមស្ដង់ដានេះ លោកប៉ូលទូលសូមព្រះជាម្ចាស់អោយផ្ដល់សេចក្ដីសុខសាន្ដដល់ពួកគេ (ខទី១៥-១៦)

នៅក្នុងខទី១៧: នៅក្នុងសេចក្ដីសន្និដ្ឋាន លោកប៉ូលមានប្រសាសន៍ថា សូមកុំអោយនរណាម្នាក់ធ្វើអោយខ្ញុំពិបាកចិត្តទៀតឡើយ ទាក់ទងនឹងសិទ្ធិអំណាចរបស់លោក ក្នុងនាមជាគ្រិស្ដទូតរបស់ព្រះគ្រិស្ដ ដ្បិតលោកមានស្លាកស្នាមរបស់ព្រះយេស៊ូនៅលើរូបកាយលោកស្រាប់ ដោយសារតែលោកជាខ្ញុំបំរើរបស់ព្រះយេស៊ូ។ តើខ្ញុំបំរើនេះជាកម្មសិទ្ធិរបស់នរណា? សូមមើលស្លាកស្នាមរបួសរបស់លោក។ ស្លាកស្នាមលើខ្លួនរបស់លោកប៉ូលដោយសារតែការបៀតបៀនគឺជាស្លាកស្នាមរបស់ព្រះគ្រិស្ដ (សូមមើល ២កូរិន ១១:២៣) (សូមមើល ២កូរិន ៩:៧-១០ និង វិវរណៈ ១៩:១១)

ក្នុងខទី១៨ "សូមព្រះគុណរបស់អម្ចាស់យេស៊ូគ្រិស្ដនៃយើង ស្ថិតនៅជាមួយវិញ្ញាណរបស់បងប្អូន។ អាម៉ែន" ពាក្យអធិស្ឋានរបស់លោកប៉ូលគឺថា ពួកគេនឹងទទួលព្រះគុណរបស់ព្រះជាម្ចាស់យ៉ាងហូរហៀរនៅក្នុងវិញ្ញាណរបស់ពួកគេ។ ហើយលោកប៉ូលនៅតែចាត់ទុកពួកគេជាបងប្អូន ទោះបីជាបន្ទាប់ពីលោកបានសរសេរលិខិតដ៏ធ្ងន់ៗបែបនេះក៏ដោយ។

Harley Voogd